**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៥៦ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## សូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៣ ស.ស.រ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ស្តីពីយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៦៨ ស.ស.រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីសេចក្តីណែនាំស្តីពីការអនុវត្តយន្តការពិគ្រោះយោបល់ និងឧបករណ៍ នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣
- យោងតាមតម្រូវការចាំបាច់ក្នុងការលើកកម្ពស់គណនេយ្យភាពទ្វេទិស និងស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការ

## សម្រេច

**ប្រការ ១.** –

ត្រូវបានដាក់ឱ្យអនុវត្តនូវសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣ ដូចមានចែងក្នុងតារាងភ្ជាប់នឹងសេចក្តីសម្រេចនេះ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិស រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងស័ក្តិសិទ្ធិភាព ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។

**ប្រការ ២.** –

ប្រគល់ភារកិច្ចជូនឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ។

**ប្រការ ៣.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃច័ន្ទ ៣ រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# សូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រយ័ត្នប្រយែង ក៏ដូចជាដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានផ្អែកលើសសរស្តម្ភទាំងបួន ដែលរួមមាន **កំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព** ដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតា ក្នុងការសម្រេចឋានៈជាប្រទេសមានចំណូលខ្ពស់ នាឆ្នាំ២០៥០ ។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, សូចនាករតាមដានរួមគ្នាត្រូវបានប្រើប្រាស់ សម្រាប់តម្រង់ទិសសកម្មភាពការងារ ដើម្បីលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ និងគណនេយ្យភាពទ្វេទិស ។ ទន្ទឹមនឹងនេះ ក៏ជាក្របខណ្ឌសម្រាប់កំណត់គោលដៅរយៈពេលមធ្យម ស្របតាមអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, កម្មវិធីកែទម្រង់, យុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា ។ តាមរយៈការពិភាក្សារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ, សូចនាករតាមដានរួមគ្នាត្រូវបានរៀបចំ ដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ ឬផែនការតាមវិស័យ និងក្របខណ្ឌលទ្ធផលរបស់វិស័យ ហើយផ្សារភ្ជាប់ជាមួយនឹងដំណើរការកម្មវិធីនីយកម្ម និងថវិកានីយកម្ម ។

សូចនាករតាមដានរួមគ្នាទាំងនេះ ដែលត្រូវបានរៀបចំ ដោយធ្វើការតម្រឹមជាមួយនឹងវិស័យអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានរំលេចអំពីសកម្មភាពអាទិភាពខ្ពស់បំផុត សម្រាប់ឆ្នាំ២០១៩-២០២០ ដែលរាជរដ្ឋាភិបាលប្តេជ្ញាអនុវត្ត ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

| **លទ្ធផលចុងក្រោយ** (២០១៩-២០២៣) | **លទ្ធផលក្នុងឆ្នាំ** (២០១៩-២០២០) | **សូចនាករលទ្ធផលក្នុងឆ្នាំ** (២០១៩-២០២០) |
|---|---|---|
| ស្នូលនៃយុទ្ធសាស្ត្រចតុកោណ : ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច – គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំ, គ្រប់គ្រង និងចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ (ទំ. ២៤) ។ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច រួមមាន ÷ ១). ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន; ២). ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ; ៣). ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង ៤). ការពង្រឹងអភិបាលកិច្ចវិស័យឯកជន (ទំ. ២៥) ។ | | |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:<br><br>បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និង ស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ | ១. ភាពជឿទុកចិត្តនៃថវិកានៅរក្សាបានជាសារវន្ត | ១.១. ការអនុវត្តចំណូលសរុប (ថ្នាក់ជាតិ- ថ្នាក់ក្រោមជាតិកម្រិតរដ្ឋបាលរាជធានី-ខេត្ត) សម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា<br>១.២. កំណើនចំណូលចរន្តប្រចាំឆ្នាំកើនឡើងយ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស<br>១.៣. តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសស្ថិតនៅក្រោម ៤០% នៃ ផ.ស.ស (បន្ទាត់មូលដ្ឋាន២០១៨: ២១,៤%)<br>១.៤. ការអនុវត្តចំណាយសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា<br>១.៥. បំណុលកកស្ទះទាបជាង ២% នៃចំណាយថវិកាសរុប (បន្ទាត់មូលដ្ឋាន២០១៨: មិនមានបំណុលកកស្ទះ)<br>១.៦. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំ (មិនមានបន្ទាត់មូលដ្ឋាន)<br>១.៧. គោលការណ៍ណែនាំស្តីពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់មកជាមួយនឹងសំណើថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>១.៨. សេចក្តីព្រាងបឋមវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២ ត្រូវបានរៀបចំ (មិនមានបន្ទាត់មូលដ្ឋាន) |
| | ២. ក្របខណ្ឌគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានរៀបចំ, អនុវត្ត និងពង្រឹង និងតម្លាភាពថវិកាត្រូវបានបង្កើន | ២.១. ចំណាត់ថ្នាក់ថវិកាចំនួន ៧ (ចំណាត់ថ្នាក់សេដ្ឋកិច្ច, អង្គភាពប្រតិបត្តិ និងរដ្ឋបាល, ភូមិសាស្ត្រ, ប្រភពមូលនិធិ, គម្រោង, កម្មវិធី និងមុខងារ) ត្រូវបានអនុវត្តពេញលេញ (បន្ទាត់មូលដ្ឋាន២០១៨: មានចំណាត់ថ្នាក់ថវិកាចំនួន ៥ អនុវត្តពេញលេញ)<br>២.២. ម៉ូឌុលចំនួន ២ បន្ថែម (រៀបចំផែនការថវិកា និងលទ្ធកម្ម) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង (បន្ទាត់មូលដ្ឋាន២០១៨: មានម៉ូឌុលស្នូលចំនួន ៦) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | ២.៣. ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់គ្រប់ក្រសួង-ស្ថាប័ន (បន្ទាត់មូលដ្ឋាន២០១៨: មានក្រសួង-ស្ថាប័នចំនួន ២០ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តចំនួន ២៥)<br>២.៤. សន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងប្រព័ន្ធពន្ធដារ ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ (បន្ទាត់មូលដ្ឋាន២០១៨: មានសន្ធានកម្មទិន្នន័យជាមួយធនាគារវឌ្ឍនៈ និងធនាគារកម្ពុ)<br>២.៥. របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដារគណនេយ្យសាធារណៈកម្ពុជា លើមូលដ្ឋានសាច់ប្រាក់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ត្រូវបានរៀបចំ (មិនមានបន្ទាត់មូលដ្ឋាន)<br>២.៦. នីតិវិធីអនុវត្តការងារសម្រាប់ការទូទាត់បៀវត្ស និងទូទាត់ត្រង់ ត្រូវបានតម្រង់ទិស និងកែលម្អ (បន្ទាត់មូលដ្ឋាន២០១៨: មាននីតិវិធីអនុវត្តការងារបច្ចុប្បន្ន និងតាមប្រព័ន្ធ FMIS របស់ក្រសួង-ស្ថាប័ន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>២.៧. ឯកសារថវិកាប្រចាំឆ្នាំត្រូវបានបោះពុម្ពផ្សាយ និងវេទិកាសាធារណៈត្រូវបានរៀបចំ |
| | ៣. ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ៣.១. ថវិកាកម្មវិធី និងអង្គភាពថវិកា ត្រូវបានអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលខេត្តចំនួន ២៤ (បន្ទាត់មូលដ្ឋាន២០១៨: មានក្រសួង-ស្ថាប័ន ចំនួន ៣៩ និងរដ្ឋបាលរាជធានី-ខេត្តចំនួន ១២ អនុវត្តថវិកាកម្មវិធី)<br>៣.២. ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង (បន្ទាត់មូលដ្ឋានឆ្នាំ២០១៨: មានសេចក្តីព្រាង MTFF)<br>៣.៣. ក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង (បន្ទាត់មូលដ្ឋាន២០១៨: មានសេចក្តីព្រាង MTBF) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | ៣.៤. ផែនការយុទ្ធសាស្ត្រថវិកា (សមាហរណកម្មថវិកា) ត្រូវបានរៀបចំ និងអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>៣.៥. សមាហរណកម្មផែនការចំណាយចរន្ត និងចំណាយវិនិយោគក្នុងសៀវភៅថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម) ត្រូវបានរៀបចំ និងអនុវត្ត<br>៣.៦. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>៣.៧. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>៣.៨. គោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាដែលមានលក្ខណៈសមាហរណកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>៣.៩. អនុក្រឹត្យស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋ ទៅរដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (មិនមានបន្ទាត់មូលដ្ឋាន)<br>៣.១០. លិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានរៀបចំ |
| | ៤. ក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៤.១. លិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ រួមមាន÷<br>- បញ្ចប់សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨<br>- កែសម្រួលអនុក្រឹត្យលេខ ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
| --- | --- | --- |
| | | ថវិការដ្ឋនៅតាមក្រសួង-ស្ថាប័ន, ខេត្ត, ក្រុង, រាជធានីភ្នំពេញស្វយ័ត និងអង្គភាពរដ្ឋបាលសាធារណៈ និងអនុក្រឹត្យលេខ ៨២ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ<br>- គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម និងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម<br>- ទម្រង់កិច្ចព្រមព្រៀងថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំ (មិនមានបន្ទាត់មូលដ្ឋាន)<br>៤.២. គោលការណ៍ណែនាំស្តីពីសវនកម្មលើសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មានត្រូវបានរៀបចំ (មិនមានបន្ទាត់មូលដ្ឋាន) |
| | ៥. សមត្ថភាពមន្ត្រីរាជការលើវិស័យហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រឹង | ៥.១. មន្ត្រីរាជការចំនួន ១.០៤៥ នាក់ នៅឆ្នាំ២០១៩ និង១.១៥០ នាក់ នៅឆ្នាំ២០២០ ចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (បន្ទាត់មូលដ្ឋាន២០១៨: ៨៥០ នាក់)<br>៥.២. សេចក្តីព្រាងឯកសារស្តីពីការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ (២០២១-២០២៥) ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត (បន្ទាត់មូលដ្ឋាន ២០១៨: យុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**<br><br>រដ្ឋបាលថ្នាក់ក្រោមជាតិផ្ដល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបានកាន់តែល្អប្រសើរ សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាព និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ១. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈថ្នាក់ក្រុង-ស្រុកត្រូវបានកែសម្រួល ដោយធ្វើសមាហរណកម្មការិយាល័យជំនាញរបស់ក្រសួង-ស្ថាប័នថ្នាក់ក្រុង-ស្រុកទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង-ស្រុក | ១.១. រដ្ឋបាលក្រុង-ស្រុកទាំងអស់បានដំណើរការ ស្របតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានកែសម្រួលជាថ្មី ដោយការិយាល័យជំនាញផ្ដល់សេវាតាមវិស័យនានា ត្រូវស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង-ស្រុក<br>(បន្ទាត់មូលដ្ឋាន២០១៨: រដ្ឋបាលក្រុង-ស្រុកពុំទាន់មានសិទ្ធិ និងការទទួលខុសត្រូវពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងការផ្ដល់សេវាតាមវិស័យនានា ដែលផ្ដល់ដោយការិយាល័យជំនាញនៅថ្នាក់ក្រុង-ស្រុក) |
| | ២. ធនធានផ្នែកអភិវឌ្ឍមូលដ្ឋាននៃមូលនិធិឃុំ-សង្កាត់ត្រូវបានបង្កើន | ២.១. ធនធានថវិការដ្ឋក្នុងអត្រា ១% នៃចំណូលចរន្តសរុបប្រចាំឆ្នាំ ត្រូវបានផ្ទេរបន្ថែមទៅមូលនិធិឃុំ-សង្កាត់ សម្រាប់ផ្នែកអភិវឌ្ឍមូលដ្ឋាន ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣<br>(បន្ទាត់មូលដ្ឋាន២០១៨: ធនធានថវិកាដែលផ្ទេរទៅមូលនិធិឃុំ-សង្កាត់ មានអត្រា ២.៨% នៃចំណូលចរន្តសរុបប្រចាំឆ្នាំ) |
| | ៣. ការងារគណនេយ្យភាពសង្គមត្រូវបានពង្រីកការអនុវត្ត ទាំងវិសាលភាពនៃតំបន់គោលដៅ និងវិសាលភាពនៃសេវាតាមវិស័យដែលត្រូវគ្របដណ្ដប់ | ៣.១. ការងារគណនេយ្យភាពសង្គម ត្រូវបានអនុវត្តនៅក្នុងស្រុកគោលដៅចំនួន ៩០% នៃចំនួនស្រុកសរុបទូទាំងប្រទេស (បន្ទាត់មូលដ្ឋាន២០១៨: ៦២%)<br>៣.២. ៨៥% នៃរដ្ឋបាលឃុំនៃចំនួនឃុំសរុបក្នុងស្រុកគោលដៅ បានអនុវត្តការងារគណនេយ្យភាពសង្គម (បន្ទាត់មូលដ្ឋាន២០១៨: ៥៩%)<br>៣.៣. ៨៥% នៃសាលាបឋមសិក្សាក្នុងស្រុកគោលដៅ បានអនុវត្តការងារគណនេយ្យភាពសង្គម (បន្ទាត់មូលដ្ឋាន២០១៨: ៥២%)<br>៣.៤. ៨៥% នៃមណ្ឌលសុខភាពក្នុងស្រុកគោលដៅ បានអនុវត្តការងារគណនេយ្យភាពសង្គម (បន្ទាត់មូលដ្ឋាន២០១៨: ៥១%) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | ៣.៥. សេវាគ្រប់គ្រងសំរាម និងសំណល់រឹងនៅទីប្រជុំជននៃស្រុកគោលដៅត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងក្របខណ្ឌនៃការអនុវត្តការងារគណនេយ្យភាពសង្គម (បន្ទាត់មូលដ្ឋាន២០១៨: 0%)<br>៣.៦. សេវាផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជននៃក្រុង និងស្រុកគោលដៅត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងក្របខណ្ឌនៃការងារគណនេយ្យភាពសង្គម (បន្ទាត់មូលដ្ឋាន២០១៨: 0%) |
| **ការកែទម្រង់រដ្ឋបាលសាធារណៈ**<br><br>ការកែលម្អការផ្ដល់សេវាសាធារណៈ និងប្រព័ន្ធគ្រប់គ្រងគុណផល ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្ដើរៗក្នុងរដ្ឋបាលសាធារណៈ ពិសេសក្នុងវិស័យសំខាន់ៗ (អប់រំ និងសុខាភិបាល) | ១. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយផ្អែកលើកំណែទម្រង់ជាដំណាក់កាល ដើម្បីធានាឱ្យបាននូវរដ្ឋបាលស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្ដោតលើប្រជាជនស្លូល | ១.១. ឯកសារទស្សនទានស្ដីពីការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាល នៅត្រីមាសទី២ ឆ្នាំ២០១៩<br>១.២. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាល នៅត្រីមាសទី៤ ឆ្នាំ២០១៩<br>១.៣. ផែនការសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត នៅត្រីមាសទី២ ឆ្នាំ២០២០<br>១.៤. របាយការណ៍តាមដានវឌ្ឍនភាពការងារកែទម្រង់ប្រចាំត្រីមាស ត្រូវបានរៀបចំ |
| | ២. ប្រព័ន្ធគ្រប់គ្រងគុណផល ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅក្នុងវិស័យ និងសេវាសាធារណៈសំខាន់ៗដែលបានកំណត់ | ២.១. គោលការណ៍ណែនាំស្ដីពីប្រព័ន្ធគ្រប់គ្រងគុណផល ត្រូវបានដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាល នៅត្រីមាសទី១ ឆ្នាំ២០២០<br>២.២. វិស័យ និងសេវាសាធារណៈសំខាន់ៗ ត្រូវបានកំណត់ និងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងគុណផល នៅត្រីមាសទី៤ ឆ្នាំ២០២០ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ៣. ការកែលម្អគុណផលនៃការផ្តល់សេវាសាធារណៈក្នុងវិស័យ និងសេវាសាធារណៈសំខាន់ៗ | ៣.១. ច្បាប់ស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៤ ឆ្នាំ២០២០<br>៣.២. សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល ត្រូវរៀបចំ និងអនុវត្ត នៅឆ្នាំ២០១៩<br>៣.៣. ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល ត្រូវអនុវត្តនៅត្រីមាសទី៣ ឆ្នាំ២០១៩<br>៣.៤. វិស័យ និងសេវាសាធារណៈសំខាន់ៗដទៃទៀត ត្រូវបានកំណត់ នៅត្រីមាសទី៤ ឆ្នាំ ២០១៩ និងដាក់ចេញនូវផែនការសកម្មភាពនៃការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ នៅត្រីមាសទី២ ឆ្នាំ២០២០ |
| **ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**<br><br>ការកែលម្អសេវាយុត្តិធម៌ និងសិទ្ធិទទួលបានសេវាយុត្តិធម៌ | ១. ច្បាប់ និងគោលនយោបាយពាក់ព័ន្ធវិស័យយុត្តិធម៌ ត្រូវបានធ្វើទំនើបកម្ម និងដាក់ឱ្យអនុវត្ត | ១.១. ការបង្កើនចំនួនចៅក្រម និងព្រះរាជអាជ្ញា (បន្ទាត់មូលដ្ឋាន២០១៨: ៤៣៧ នាក់; ចំណុចដៅ: បង្កើន ១០% រៀងរាល់ឆ្នាំ)<br>១.២. សន្ទស្សន៍នីតិរដ្ឋតាមគម្រោងយុត្តិធម៌ពិភពលោកត្រូវបានបង្កើន (បន្ទាត់មូលដ្ឋាន ២០១៧-២០១៨: ០,៣២; ចំណុចដៅ២០២៣: ០,៤០)<br>១.៣. ភាពចង្អៀតណែនក្នុងពន្ធនាគារត្រូវបានកាត់បន្ថយ (បន្ទាត់មូលដ្ឋាន២០១៥: ២៦២% នៃអាត្រាអ្នកជាប់ពន្ធនាគារ; ចំណុចដៅ: ២០០%)<br>១.៤. បង្កើនថវិកាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ (បន្ទាត់មូលដ្ឋាន២០១៩: ៣០០.០០០ ដុល្លារ; ចំណុចដៅ: បង្កើន ២៥% រៀងរាល់ឆ្នាំ)<br>១.៥. សេចក្តីព្រាងច្បាប់អាជ្ញាសាលា, សាការី និងក្រឡាបញ្ជី និងនីតិវិធីតាក់តែងសេចក្តីព្រាងច្បាប់ ឬស្មើច្បាប់, សេចក្តីព្រាងច្បាប់ការពារសាក្សី និងការពារអ្នករាយការណ៍ ត្រូវបាន |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | តាក់តែង តាមរយៈដំណើរការប្រកបដោយតម្លាភាព និងពិគ្រោះយោបល់ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ៤)<br>១.៦. វិសោធនកម្មក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ នឹងត្រូវដំណើរការដោយតម្លាភាព និងមានការពិគ្រោះយោបល់ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ២)<br>១.៧. វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានអនុម័ត<br>១.៨. ពិរុទ្ធជនដែលត្រូវឃុំខ្លួនបណ្តោះអាសន្ន គិតជាសមាមាត្រនៃអ្នកជាប់ឃុំទាំងអស់ (បន្ទាត់មូលដ្ឋាន: ៦៥%; ចំណុចដៅ: ៤៥ %)<br>១.៩. អ្នកទោសដែលមានសាលក្រមស្ថាពរ គិតជាសមាមាត្រធៀបនឹងអ្នកជាប់ឃុំ (បន្ទាត់មូលដ្ឋាន២០១៨: ២៩%; ចំណុចដៅ: ៤៩%)<br>១.១០. ចំនួនអ្នកត្រូវផ្តន្ទាទោសដែលសម្រេចមិនឃុំខ្លួន (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ៥០)<br>១.១១. ចំនួនស្ត្រីដែលត្រូវបានផ្តន្ទាទោសដោយមិនឃុំខ្លួន (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ៥) |
| | ២. ការរៀបចំអង្គការតុលាការត្រូវបានពង្រឹង | ២.១. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណុំរឿង/ការចុះបញ្ជីសំណុំរឿង ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ១)<br>២.២. ការបង្កើតសាលាឧទ្ធរណ៍តំបន់ (បន្ទាត់មូលដ្ឋាន: ១; ចំណុចដៅ: ៣)<br>២.៣. ការបង្កើតសូចនាករវាយតម្លៃការបំពេញការងាររបស់តុលាការទាំងអស់ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ: ១)<br>២.៤. ការសិក្សាស្រាវជ្រាវពីសុចរិតភាពតុលាការ បានអនុវត្ត (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ:១) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ៣. ការគ្រប់គ្រងសំណុំរឿង និងព័ត៌មាន ត្រូវបានកែលម្អ | ៣.១. សំណុំរឿងកកស្ទះនៅតាមសាលាដំបូង ត្រូវបានកាត់បន្ថយ (បន្ទាត់មូលដ្ឋាន: ៤២% សម្រាប់រឿងរដ្ឋប្បវេណី និង ៨៧% សំរាប់រឿងព្រហ្មទណ្ឌ; ចំណុចដៅ: ៣៨% សម្រាប់រឿងរដ្ឋប្បវេណី និង ៧៨% សម្រាប់រឿងព្រហ្មទណ្ឌ)<br>៣.២. របាយការណ៍វាយតម្លៃពីការចុះបញ្ជីការតុលាការនៅតាមសាលាដំបូង ត្រូវបានបញ្ចប់ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ១)<br>៣.៣. ចំនួនសាលក្រមព្រហ្មទណ្ឌសម្រាំងបានបោះពុម្ព (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥០)<br>៣.៤. ចំនួនសាលក្រមរដ្ឋប្បវេណីសម្រាំងបានបោះពុម្ព (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥០) |
| ការប្រយុទ្ធប្រឆាំងអំពើពុករលួយ*<br><br>បង្កើនសុចរិតភាពសាធារណៈ, សាជីវកម្ម និងសង្គម | ១. ការកំណត់ក្របខណ្ឌច្បាប់ វិធានការថ្មី និងវិធានការចាស់ដែលត្រូវធ្វើវិសោធនកម្ម សម្រាប់បង្ការទប់ស្កាត់អំពើពុករលួយ | ១.១. របាយការណ៍ស្វ័យវាយតម្លៃពីច្បាប់ និងការអនុវត្តច្បាប់ទាក់ទងនឹងការបង្ការទប់ស្កាត់អំពើពុករលួយ ត្រូវបានរៀបចំ និងអនុម័តក្នុងឆ្នាំ ២០១៩ |
| | ២. ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានផ្តល់ជូនដល់និស្សិតនៅតាមគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងសិស្សសាលាវិជ្ជាជីវៈសាធារណៈ | ២.១. មេរៀនស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់សិស្ស-និស្សិត និងគ្រូនៅតាមគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងសិស្សសាលាវិជ្ជាជីវៈសាធារណៈ ត្រូវបានរៀបចំ<br>២.២. ចំនួនគ្រូបង្គោលទទួលការបណ្តុះបណ្តាលមេរៀនអប់រំស្តីពីការប្រឆាំងអំពើពុករលួយ គិតត្រឹមចុងឆ្នាំ ២០២០<br>២.៣. ចំនួនសិស្ស-និស្សិតនៅតាមគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងសិស្សសាលាវិជ្ជាជីវៈសាធារណៈទទួលការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ត្រឹមចុងឆ្នាំ ២០២០ |

*សូចនាករតាមដានត្រូវបានកំណត់ដោយអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ៣. ចំណាយសាធារណៈធ្វើឡើងប្រកបដោយប្រសិទ្ធភាព និងតម្លាភាព | ៣.១. ចំនួនក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ ដែលអង្គភាពប្រឆាំងអំពើពុករលួយចូលរួមសង្កេតការណ៍ក្នុងការងារលទ្ធកម្មសាធារណៈ និងកិច្ចការផ្សេងៗពាក់ព័ន្ធចំណាយរដ្ឋ<br>៣.២. ចំនួនស្ថាប័នសាធារណៈ និងឯកជន ដែលទទួលបានការបណ្តុះបណ្តាលច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ |
| **ផែនការ និងការកាត់បន្ថយភាពក្រីក្រ**<br><br>គោលដៅអាទិភាពជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាសម្រេចបាន តាមរយៈការអនុម័ត និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយការអនុវត្តនេះ ត្រូវបានវាយតម្លៃដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រកបដោយគុណភាព ដែលជាផ្នែកមួយនៃប្រព័ន្ធតាមដាន,ត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព | ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានអនុវត្តពេញលេញ ជាមួយគ្នានឹងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល, ការរៀបចំផែនការ និងយន្តការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានពង្រឹង ហើយរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តឆ្នាំ២០១៩ ត្រូវបានរៀបចំ និងអនុម័ត | ១.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានរៀបចំ និងអនុម័ត<br>១.២ កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ត្រូវបានរៀបចំតាមវដ្តនៃការរៀបចំ និងស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ហើយកម្មវិធីវិនិយោគសាធារណៈ ត្រូវបានប្រើប្រាស់ជាឯកសារយោង សម្រាប់រៀបចំថវិកាជាតិប្រចាំឆ្នាំ<br>១.៣ របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំបញ្ចប់, បោះពុម្ព និងផ្សព្វផ្សាយទូទាំងប្រទេស<br>១.៤ យុទ្ធសាស្ត្រជាតិស្តីពីការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានបញ្ចប់ និងអនុម័ត<br>១.៥ ពង្រឹងសុខដុមនីយកម្មរវាងផែនការថវិកា និងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ (តាមរយៈការផ្សារភ្ជាប់រវាងការរៀបចំផែនការ និងការរៀបចំថវិកា)<br>១.៦ ភស្តុតាងត្រូវបានបង្កើតឡើង ដើម្បីជូនដំណឹងដល់ការរៀបចំអន្តរាគមន៍នានា សម្រាប់កាត់បន្ថយភាពក្រីក្រ និងរបាយការណ៍ស្តីពីការវាស់វែងភាពក្រីក្រ រួមទាំងរបាយការណ៍ភាពក្រីក្រពហុវិមាត្រ និងភាពក្រីក្ររបស់កុមារ ត្រូវបានរៀបចំ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ២. ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានអនុវត្តតាមរយៈ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ និងតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការសម្រេចបាន។ | ២.១ ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ<br>២.២ របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ នៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ត្រូវបានរៀបចំ និងបង្ហាញនៅក្នុងវេទិកាកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ<br>២.៣ របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាពកម្ពុជា ត្រូវបានរៀបចំ និងអនុម័ត<br>២.៤ វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅថ្នាក់ក្រោមជាតិ ត្រូវបានតាមដាន និងត្រួតពិនិត្យ |
| | ៣. អាទិភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍស្ថិតិ ឆ្នាំ២០១៩-២០២៣ | ៣.១ ជំរឿនទូទៅនៃប្រជាជនកម្ពុជា ឆ្នាំ២០១៩<br>៣.២ កម្មវិធីជាតិសម្រាប់រាយការណ៍សូចនាករអភិវឌ្ឍន៍ (CAMStat) រួមទាំងទម្រង់ផ្សព្វផ្សាយទិន្នន័យសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/ គោលដៅជ្រើសរើសមួយចំនួន ត្រូវបានអនុវត្តពេញលេញ<br>៣.៣ ការអង្កេតដទៃទៀត<br>៣.៤ របាយការណ៍ស្ថិតិគន្លឹះៗ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ភាពជាដៃគូ និងសុខដុមនីយកម្ម**<br><br>ការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ប្រកបដោយស័ក្តិសិទ្ធិភាព ដើម្បីសម្រេចគោលដៅអាទិភាពអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | ១. ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពជាតិ | ១.១. ហិរញ្ញប្បទានសហប្រតិបត្តិការ គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>- តម្រូវការហិរញ្ញប្បទានសហប្រតិបត្តិការសរុប សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (បន្ទាត់មូលដ្ឋាន២០១៨: ១,៣៨៣ពាន់លានដុល្លារ; ចំណុចដៅ២០២០: ១,៦៩ ពាន់លានដុល្លារ)<br>- ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការ គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ប្រមាណ ៩០% នៃចំណុចដៅ ឆ្នាំ២០២០)<br>១.២. ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិ (បន្ទាត់មូលដ្ឋាន២០១៨: ៦៤%; ចំណុចដៅ២០២០: ៧២%) |
| | ២. ការអនុវត្តយន្តការពិគ្រោះយោបល់ និងឧបករណ៍ នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាព ក្នុងការសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ | ២.១. យន្តការពិគ្រោះយោបល់:<br>- កិច្ចពិគ្រោះយោបល់ទ្វេភាគី (បន្ទាត់មូលដ្ឋាន: តាមវដ្តនៃកម្មវិធីសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ; ចំណុចដៅ: ៥ ដង ក្នុង ១ឆ្នាំ)<br>- កិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ (ចំណុចដៅ: ១ ដង ក្នុង១ឆ្នាំ)<br>- កិច្ចពិគ្រោះយោបល់ពហុភាគីក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ [កម្រិតវិស័យ/ក្រុមការងារបច្ចេកទេសចម្រុះ/អង្គការមិនមែនរដ្ឋាភិបាល/កិច្ចពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ] (ចំណុចដៅ: ២ ដង សម្រាប់យន្តការនីមួយៗ)<br>២.២. ការប្រមូលសរុបសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣ និងរបាយការណ៍វឌ្ឍនភាព (ចំណុចដៅ១: សូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័ត នាត្រីមាសទី៣ ឆ្នាំ២០១៩; ចំណុចដៅ ២: របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តសូចនាករ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | តាមដានរួមគ្នា ត្រូវបានរៀបចំ នាឆ្នាំ២០២១)<br>២.៣. ភាពជាដៃគូសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ឬការអង្កេតសកលទីក្រុងប៊ូសាន (ចំណុចដៅ: ការចូលរួមធ្វើអង្កេតភាពជាដៃគូសកលទីក្រុងប៊ូសានស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០១៩) |
| | ៣. វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវបានពិនិត្យ និងតាមដាន ដើម្បីធានាបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ | ៣.១. របាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងការពិនិត្យវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ (ចំណុចដៅ: របាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ) |
| **ចតុកោណទី ១ : <u>ការអភិវឌ្ឍធនធានមនុស្ស</u>** - ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពទី ១ នៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, សំដៅលើកកម្ពស់ចំណេះដឹង, ជំនាញ, វិជ្ជាជីវៈ, សមត្ថភាពសហគ្រិនភាព, ការច្នៃប្រឌិត, នវានុវត្តន៍, គុណធម៌, សីលធម៌, មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ, សុខភាពល្អ និងកាយសម្បទារឹងមាំ, តួនាទីស្ត្រី និងកិច្ចគាំពារសង្គម ។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សក្នុងនីតិកាលទី ៦ នឹងបន្តផ្តោតលើ ១). ការពង្រឹងគុណភាពវិស័យអប់រំ, វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា; ២). ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ៣). ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤). ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម (ទំ. ៤២-៤៣) ។ | | |
| | ១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះ ពិសេសនៅថ្នាក់ដំបូង | ១.១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះពី ៦,២% (ប្រុស ៧,៧%-ស្រី ៤,៧%) ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ៥,៧% (ប្រុស៦,៨%-ស្រី ៤,១%) ក្នុងឆ្នាំសិក្សា ២០១៩-២០២០ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **វិស័យអប់រំ**<br><br>អត្រាបញ្ចប់ការសិក្សានៅកម្រិតអប់រំមូលដ្ឋានកើនឡើង ជាមួយនឹងលទ្ធផលនៃការសិក្សាប្រសើរឡើង | ២. លទ្ធផលសិក្សារបស់សិស្សនៅបឋមសិក្សាកើនឡើង (អំណាន និង គណិតវិទ្យាថ្នាក់ទី ៣ - ការសរសេរ និងគណិតវិទ្យាថ្នាក់ទី៦) | ២.១. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" នៅថ្នាក់ទី៣:<br>- អំណាន: ថយចុះពី ៥២,៦% ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ដល់ ៤៦,៦% ក្នុងឆ្នាំសិក្សា ២០១៩-២០២០<br>- គណិតវិទ្យា: ថយចុះពី ៤៤,៩% ឆ្នាំសិក្សា ២០១៤-២០១៥ ដល់ ៣៨,៩% ក្នុងឆ្នាំសិក្សា ២០១៩-២០២០<br>២.២. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" នៅថ្នាក់ទី៦:<br>- ការសរសេរ: ថយចុះពី ៣៩,៦% ក្នុងឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៣៣,៦% ក្នុងឆ្នាំសិក្សា ២០២០-២០២១<br>- គណិតវិទ្យា: ថយចុះពី ៥៣,២% ឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៤៧,២% ក្នុងឆ្នាំសិក្សា ២០២០-២០២១ |
| | ៣. អត្រានៃការសិក្សាកើនឡើង និង អត្រាបោះបង់ការសិក្សាថយចុះនៅមធ្យមសិក្សាបឋមភូមិ | ៣.១. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (GER) កើនពី ៥៩,១% (ប្រុស ៥៤,៩%-ស្រី ៦៣,៨%) ឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ៦២,២% (ប្រុស ៥៩,១%-ស្រី ៦៦,៨%) ក្នុងឆ្នាំសិក្សា ២០១៩-២០២០<br>៣.២. អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ថយចុះពី ១៥,៨% (ប្រុស ១៧,៦%-ស្រី ១៤,២%) ឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ១២,៨% (ប្រុស ១៣,៨%-ស្រី ១១,៧%) ក្នុងឆ្នាំសិក្សា ២០១៩-២០២០ ។ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**<br><br>បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងពង្រឹងគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ | ១. ពង្រឹងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ | ១.១. ចំនួនសិក្ខាកាម, សិស្ស និងនិស្សិតបានបញ្ចប់ការបណ្តុះបណ្តាល មានការងារធ្វើយ៉ាងតិច ៧០% (ចំណុចដៅឆ្នាំ២០២០: ៧០%)<br>១.២. ភាគរយនៃការពេញចិត្តរបស់និយោជក លើសិក្ខាកាម, សិស្ស និងនិស្សិត ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ចំណុចដៅឆ្នាំ២០២០: ៧០%)<br>១.៣. ភាគរយគ្រូបច្ចេកទេសនៃគ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជនដែលបានចុះបញ្ជី ទទួលបានការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) មានការកើនឡើង ១៨%/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០១៨: ២៤៤) |
| | ២. ពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | ២.១. សិក្ខាកាមទទួលបានការបណ្តុះបណ្តាលវគ្គខ្លី និងការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់យ៉ាងតិច ៣៩.០០០ នាក់/ឆ្នាំ ពីគ្រឹះស្ថានសាធារណៈ និងឯកជន អត្រាស្ត្រីចំនួនយ៉ាងតិច ៥០% (បន្ទាត់មូលដ្ឋាន២០១៨:៤៩.៦៦២ ចំណុចដៅ២០២០: ៧៨.០០០)<br>២.២. ការចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ៣ (CQF 1 2 3 4) និងសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស (CQF 5) កើនឡើងយ៉ាងតិច២០%/ឆ្នាំ អត្រាស្ត្រីយ៉ាងតិច ២៥% (បន្ទាត់មូលដ្ឋាន២០១៨ កម្រិត២: ១.៩៩៥ កម្រិត៣: ៤៩១ កម្រិត៤: ៣៩៨ កម្រិត៥: ៤.៩០៨; ចំណុចដៅ២០១៩-២០២០ កម្រិត១: ១០០ កម្រិត២: ៥.២៦៦ កម្រិត៣: ១.២១៦ កម្រិត៤: ១.០៤៩ កម្រិត៥: ១២.៩៥៥)<br>២.៣. អត្រាការចុះឈ្មោះនៃការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL/RCC) លើជំនាញអាទិភាព មានការកើនឡើង, យ៉ាងតិច ៧០% នៃអ្នកមកធ្វើតេស្តវាយតម្លៃសមត្ថភាពជាប់ (ចំណុចដៅ២០១៩:៥០, ២០២០:១០០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ៣.១. គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន១៥/ឆ្នាំ (ចំណុចដៅ២០២០ : ៣០)<br>៣.២. សិស្ស-និស្សិតបានចុះកម្មសិក្សាតាមសហគ្រាស-គ្រឹះស្ថាន យ៉ាងតិចចំនួន ២.៥០០នាក់/ឆ្នាំ (បន្ទាត់មូលដ្ឋាន២០១៨: ១.៧៥៤ ចំណុចដៅ២០១៩-២០២០: ៥.០០០)<br>៣.៣. សិស្សទទួលបានការបណ្តុះបណ្តាលក្នុងកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) យ៉ាងតិចចំនួន ៤០០នាក់/ឆ្នាំ (បន្ទាត់មូលដ្ឋាន២០១៨: ៤១០ ចំណុចដៅ២០២០: ៨០០) |
| **វិស័យសុខាភិបាល**<br>ប្រព័ន្ធសុខាភិបាលជាតិដំណើរការល្អ និងធានានិរន្តរភាព បង្កើតបានលទ្ធផលល្អប្រសើរលើផ្នែកសុខភាព អាហារូបត្ថម្ភ និងសុខុមាលភាព សម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសជនក្រីក្រ, ជនងាយរងគ្រោះ, ស្ត្រី និងកុមារ | ១. ធ្វើឱ្យប្រសើរឡើងនូវសុខភាពបន្តពូជ, សុខភាពមាតា, កុមារ និងទារកតាមរយៈការពង្រឹងគុណភាព និងស័ក្តិសិទ្ធិភាពនៃសេវាថែទាំសុខភាព | ១.១. សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល ៨៤% នាឆ្នាំ២០១៨ នឹងរំពឹងថាកើនដល់:<br>- ៨៩%ក្នុងឆ្នាំ២០១៩ (ចំណុចដៅនេះរួមបញ្ចូលទិន្នន័យមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន យោងតាមផែនការយុទ្ធសាស្ត្រសុខាភិបាល២០១៦-២០២០)<br>- ៩០%ក្នុងឆ្នាំ២០២០ (ចំណុចដៅនេះរួមបញ្ចូលទិន្នន័យមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន យោងតាមផែនការយុទ្ធសាស្ត្រសុខាភិបាល២០១៦-២០២០) |
| **ជម្ងឺអេដស៍**<br>គោលដៅលុបបំបាត់ការរាលដាលនៃមេរោគអេដស៍ មិនឱ្យក្លាយជាការគម្រាមកំហែងសុខភាពសាធារណៈ ត្រឹមឆ្នាំ ២០២៥ ដោយសម្រេចបានគោលដៅ ៩៥-៩៥-៩៥ | ១. សម្រេចឱ្យបានគោលដៅ ៩២-៩២-៩២ | ១.១. ៩២% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដឹងពីស្ថានភាពរបស់ខ្លួន (បន្ទាត់មូលដ្ឋាន ២០១៨: ៨២%)<br>១.២. ១០០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលដឹងពីស្ថានភាពរបស់ខ្លួន ទទួលបានការព្យាបាល (បន្ទាត់មូលដ្ឋាន២០១៨: ៩៩%)<br>១.៣. ១០០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលដឹងពីស្ថានភាពរបស់ខ្លួន ហើយទទួលបានការព្យាបាល មានបរិមាណមេរោគក្នុងឈាមទាប មិនអាចបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ (បន្ទាត់មូលដ្ឋាន២០១៨: ៩៥%) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ២. អត្រាគ្របដណ្តប់ដោយកម្មវិធីគាំពារសង្គមលើអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈម | ២.១. ៨០% នៃអ្នកផ្ទុកមេរោគអេដស៍ដែលទទួលបានការព្យាបាល បានចុះឈ្មោះក្នុងកម្មវិធីគាំពារសង្គម (បន្ទាត់មូលដ្ឋាន២០១៨: ១៨%) |
| | ៣. កំណើនថវិកាក្នុងស្រុកសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | ៣.១. ៣៥% នៃការចំណាយលើការងារអេដស៍ បានមកពីថវិកាក្នុងស្រុក ត្រឹមឆ្នាំ២០២០ (បន្ទាត់មូលដ្ឋាន២០១៥: ១៧%) |
| **វិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**<br><br>ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាគ្រប់រូប ពិសេសជនក្រីក្រ, អសន្តិសុខស្បៀង និងជនងាយរងគ្រោះ ត្រូវបានលើកកម្ពស់ តាមរយៈប្រសិទ្ធភាពនៃការសម្របសម្រួល និងប្រព័ន្ធនៃការផ្តល់សេវា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១. យុទ្ធសាស្ត្រ និងក្របខណ្ឌសម្រាប់បង្កើនប្រសិទ្ធភាព និងសកម្មភាពពហុវិស័យ ដើម្បីបញ្ចប់ភាពស្រេកឃ្លាន និងលុបបំបាត់បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ត្រឹមឆ្នាំ ២០៣០ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ផែនការសកម្មភាព ដើម្បីកាត់បន្ថយភាពស្រេកឃ្លានដល់កម្រិតសូន្យ, បណ្តាញចលនាបង្កើនអាហារូបត្ថម្ភ) ត្រូវបានសម្របសម្រួល និងធ្វើសុខដុមនីយកម្ម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១.១. យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៩-២០២៣ ត្រូវបានផ្សព្វផ្សាយ និងផ្តល់ការណែនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រឹមឆ្នាំ២០២០<br>១.២. របាយការណ៍វាយតម្លៃប្រចាំឆ្នាំ ត្រូវបានរៀបចំ និងផ្ញើជូនលេខាធិការដ្ឋានចលនាបង្កើនអាហារូបត្ថម្ភពិភពលោក (របាយការណ៍ចំនួន២ ត្រូវបានដាក់ជូនក្នុងកំឡុងឆ្នាំ ២០១៩-២០២០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ២. យន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជានាសង្គតិភាព រវាងការផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ត្រូវបានពង្រឹង | ២.១. រៀបចំផែនការថ្នាក់ជាតិស្ដីពីសកម្មភាពអាទិភាពរួមគ្នារវាងការផ្គត់ផ្គង់ទឹកស្អាត, អនាម័យ និងអាហារូបត្ថម្ភត្រឹមឆ្នាំ២០២០<br>២.២. សេចក្ដីណែនាំ និងឧបករណ៍សម្រាប់យុទ្ធនាការផ្លាស់ប្ដូរឥរិយាបថ ត្រូវបានរៀបចំដើម្បីសង្គតិភាពរវាងការផ្គត់ផ្គង់ទឹកស្អាត, អនាម័យ និងអាហារូបត្ថម្ភ ហើយត្រូវអនុវត្តសាកល្បងក្នុងខេត្តចំនួន៤ ត្រឹមឆ្នាំ២០២០ |
| | ៣. ពង្រឹងយន្តការដែលមានស្រាប់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនភាពមានស្បៀង, លើកកម្ពស់ការប្រើប្រាស់ស្បៀង និងកាត់បន្ថយវិសមភាពក្នុងការទទួលបានស្បៀងគ្រប់គ្រាន់ និងប្រកបដោយអាហារូបត្ថម្ភ និងចម្រុះ និងគាំពារសន្តិសុខស្បៀង និងអាហារូបត្ថម្ភពីភាពតានតឹង និងវិបត្តិនានា | ៣.១. សេចក្ដីណែនាំ និងយន្តការនានា ត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ប្រព័ន្ធស្បៀងដែលគិតគូរពីអាហារូបត្ថម្ភ, កាត់បន្ថយគ្រោះមហន្តរាយ, ទប់ស្កាត់ជំងឺសត្វ និងដំណាំ និងរៀបចំវិធានការឆ្លើយតបទៅនឹងគ្រោះអាសន្ន និងការប្រែប្រួលអាកាសធាតុ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **សមភាពយេនឌ័រ**<br>យន្តការស្ថាប័ន និងការសម្របសម្រួលពហុភាគី លើការងារសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ត្រូវបានពង្រឹង តាមរយៈក្របខណ្ឌគោលនយោបាយស្តីពីយេនឌ័រ និងកម្មវិធីជាតិសម្រាប់បង្ការ និងឆ្លើយតបលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី, ភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច | ១. គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល និងត្រូវបានអនុវត្ត ស្របតាមការប្តេជ្ញាចិត្តជាតិ និងអន្តរជាតិសម្រាប់ពង្រឹងសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ១.១. សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័របានកែសម្រួលបញ្ចប់ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងទទួលបានការអនុម័តដោយរាជរដ្ឋាភិបាល (បន្ទាត់មូលដ្ឋាន: មិនទាន់មាន; ចំណុចដៅ២០១៩: ចំនួន១)<br>១.២. ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រនៅតាមក្រសួង-ស្ថាប័ន និងតាមវិស័យបានរៀបចំ តាមរយៈយន្តការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងចូលរួមអនុវត្តដោយក្រសួង-ស្ថាប័ននានា (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ២០២០: ១)<br>១.៣. ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ បានដាក់តែង និងប្រើប្រាស់ក្នុងការពង្រឹងប្រសិទ្ធភាព និងមុខងាររបស់ក្រសួងកិច្ចការនារី និងអង្គភាពចំណុះរបស់ខ្លួន (បន្ទាត់មូលដ្ឋាន: ៤; ចំណុចដៅ២០១៩: ៥) |
| | ២. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ឆ្នាំ២០១៩-២០២៣ បានដាក់ឱ្យដំណើរការ ហើយការវាយតម្លៃលើការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ សម្រាប់ផ្តល់ជាធាតុចូលដល់កម្មវិធីកំណែទម្រង់ច្បាប់ ដើម្បីលើកកម្ពស់ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី | ២.១. សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ បានពិគ្រោះយោបល់ និងអនុម័តដោយគណៈរដ្ឋមន្ត្រី ។ ផែនការសកម្មភាព និងថវិការបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ និងចូលរួមឆ្លើយតបនឹងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (បន្ទាត់មូលដ្ឋាន: ២; ចំណុចដៅ២០១៩: ៣)<br>២.២. ប្រព័ន្ធតាមដាននៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី, ផែនការសកម្មភាព និងថវិកាក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ និងចែករំលែកនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសយេនឌ័រស្តីពីការទប់ស្កាត់អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (បន្ទាត់មូលដ្ឋាន: ២; ចំណុចដៅ២០២០: ៣)<br>២.៣. ការប៉ាន់ប្រមាណលើការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ច |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | ការពារជនរងគ្រោះ ត្រូវបានរៀបចំ និងចែករំលែករបកគំហើញនៃការប៉ាន់ប្រមាណ ដល់តួអង្គពាក់ព័ន្ធ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ២០២០: ១)<br>២.៤. ផែនទីចង្អុលផ្លូវ និងធាតុចូលសំខាន់ៗសម្រាប់កម្មវិធីកំណែទម្រង់ច្បាប់ បានឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយប្រើប្រាស់របកគំហើញនៃការប៉ាន់ប្រមាណលើការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ២០២០: ១) |
| | ៣. កម្មវិធីជាតិស្ដីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ត្រូវបានអនុវត្តពេញលេញ សម្រាប់ពង្រឹងសមភាពយេនឌ័រក្នុងតួនាទីធ្វើសេចក្ដីសម្រេច | ៣.១. កម្មវិធីជាតិស្ដីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី បានតាក់តែង និងទទួលបានថវិការដ្ឋ និងធនធានពីដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្ត (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ២០១៩: ១)<br>៣.២. បណ្ដាញសហគ្រិនស្ត្រីនៅកម្ពុជា ត្រូវបានបង្កើត និងដំណើរការ ដើម្បីលើកកម្ពស់បណ្ដាញទំនាក់ទំនង, ការចែករំលែកព័ត៌មាន, ចំណេះដឹង និងបញ្ហាប្រឈមនានា របស់ស្ត្រីជាសហគ្រិន និងលើកកម្ពស់យេនឌ័រក្នុងធុរកិច្ចនៅកម្ពុជា, ក្នុងតំបន់អាស៊ាន និងលើឆាកអន្តរជាតិ (បន្ទាត់មូលដ្ឋាន: ០; ចំណុចដៅ២០១៩: ១)<br>៣.៣. អនុក្រុមការងារបច្ចេកទេសយេនឌ័រ ស្ដីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច បានដំណើរការប្រកបដោយប្រសិទ្ធភាព ក្នុងការកៀរគរការគាំទ្រពីដៃគូពាក់ព័ន្ធ ដើម្បីឈានទៅសម្រេច និងតាមដានគោលដៅជាតិលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងតួនាទីធ្វើសេចក្ដីសម្រេច ដូចមានចែងក្នុងគោលដៅទី៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (បន្ទាត់មូលដ្ឋាន: ១; ចំណុចដៅ២០១៩: ២) |

| លទ្ធផលចុងក្រោយ<br>(២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ<br>(២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ<br>(២០១៩-២០២០) |
|---|---|---|
| **ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ**<br><br>ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ-ជំហាន ២ (NAP II) : ត្រឹមឆ្នាំ ២០២៣ កំណើនប្រជាពលរដ្ឋនៅជនបទទទួលបាន និងប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយសមធម៌ និងសុវត្ថិភាព<br><br>គោលដៅ NAP II:<br>- ៩០% មានលទ្ធភាពទទួលបានអនាម័យជនបទដែលមានការកែលម្អ<br>- ៩០% មានលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតជនបទដែលមានការកែលម្អ | ១. សមត្ថភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត, ក្រុមការងារទឹកស្អាត និងអនាម័យខេត្ត និងអាជ្ញាធរមូលដ្ឋាន ត្រូវបានពង្រឹង សម្រាប់ការរៀបចំផែនការ និងការសម្របសម្រួល ដើម្បីកៀរគរថវិកាបន្ថែម និងពិនិត្យតាមដានកម្មវិធី RWSSH រួមទាំងកម្មវិធីទឹកស្អាត និងអនាម័យនៅតាមស្ថាប័ន (សាលារៀន និងមណ្ឌលសុខភាព) និងក្នុងពេលមានគ្រោះអាសន្ន | ១.១. ចំនួនក្រុមការងារទឹកស្អាត និងអនាម័យខេត្ត បានរៀបចំកិច្ចប្រជុំយ៉ាងតិចបីដង រួមទាំងកិច្ចប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃ PAP II; កិច្ចប្រជុំយ៉ាងតិចមួយបានដាក់បញ្ចូលរបៀបវារៈអំពី WASH និងអាហារូបត្ថម្ភ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ WASH MIS: ២៥)<br>១.២. ចំនួនខេត្តយ៉ាងតិច ៥០% នៃសូចនាករ PAP II ស្តីពីលទ្ធផលនៃការអនុវត្ត RWSSH ត្រូវបានប្រមូល និងកត់ត្រាទុកនៅក្នុង RWSSH MIS ថ្នាក់ជាតិ (បន្ទាត់មូលដ្ឋាន: N/A; ចំណុចដៅ WASH MIS: 25)<br>១.៣. ចំនួនគោលការណ៍ណែនាំ បានបង្កើត និងអនុម័ត (បន្ទាត់មូលដ្ឋាន: N/A; ចំណុចដៅ WASH MIS: ៥)<br>១.៤. ចំនួនស្រុកដែលមានការវិភាជថវិកាសម្រាប់ RWSSH ក្នុងផែនការវិនិយោគស្រុក (បន្ទាត់មូលដ្ឋាន: ១៥; ចំណុចដៅ WASH MIS: ៣០) |
| | ២. ប្រជាជននៅជនបទ និងអ្នករស់នៅក្នុងតំបន់មានបរិស្ថានប្រឈម និងតំបន់ប៉ះពាល់ដោយសារធាតុអាសេនិក ទទួលបានសេវាផ្គត់ផ្គង់ទឹកបរិភោគ ប្រកបដោយសមធម៌ សុវត្ថិភាព និងចីរភាព មានចំនួនកើនឡើង | ២.១. ចំនួនប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមទុយោដែលធន់នឹងអាកាសធាតុ ដែលគ្រប់គ្រងដោយសហគមន៍ អនុលោមតាមសៀវភៅណែនាំរចនាបច្ចេកទេស និងការត្រួតពិនិត្យការសាងសង់ (បន្ទាត់មូលដ្ឋាន: TBC; ចំណុចដៅ WASH MIS: ២០០)<br>២.២. ចំនួនឃុំដែលអនុវត្តផែនការសុវត្ថិភាពទឹក ដែលធន់នឹងអាកាសធាតុ ដោយផ្អែកលើគោលការណ៍ណែនាំជាតិសម្រាប់អនុវត្តផែនការសុវត្ថិភាពទឹកនៅជនបទ (បន្ទាត់មូលដ្ឋាន: ២៨; ចំណុចដៅ WASH MIS: ២៥០)<br>២.៣. ចំនួនខេត្តដែលមានរបាយការណ៍ប្រចាំឆ្នាំ អំពីការត្រួតពិនិត្យតាមដានគុណភាពទឹក ផ្អែក |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | | លើគោលការណ៍ណែនាំជាតិសម្រាប់គុណភាពទឹកផឹក (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ WASH MIS: ៥) |
| | ៣. ប្រជាជននៅជនបទ និងអ្នករស់នៅក្នុងតំបន់មានបរិស្ថានប្រឈមទទួលបានសេវាអនាម័យ ដែលគ្រប់គ្រងដោយសុវត្ថិភាព ប្រកបដោយសមធម៌ និងនិរន្តរភាព មានចំនួនកើនឡើង | ៣.១. ចំនួនឃុំបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (បន្ទាត់មូលដ្ឋាន: ៧២; ចំណុចដៅ WASH MIS: ២៨៣)<br>៣.២. ចំនួនស្រុកបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (បន្ទាត់មូលដ្ឋាន: ២; ចំណុចដៅ WASH MIS: ១៣)<br>៣.៣. ចំនួនស្រុកដែលមានសហគ្រិនផ្គត់ផ្គង់ផលិតផល និងសេវាអនាម័យជាមូលដ្ឋាន (បន្ទាត់មូលដ្ឋាន: ១៧៤; ចំណុចដៅ WASH MIS: ១៨៥) |
| | ៤. ប្រជាជននៅជនបទផ្លាស់ប្តូរឥរិយាបទ និងប្រតិបត្តិអនាម័យល្អ ទាក់ទងនឹងការផឹកទឹកសុវត្ថិភាព, ការប្រើប្រាស់បង្គន់អនាម័យ និងការលាងដៃជាមួយនឹងសាប៊ូ | ៤.១. ចំនួនឃុំដែលលើកកម្ពស់ការគ្រប់គ្រងអនាម័យពេលមករដូវ (បន្ទាត់មូលដ្ឋាន: N/A; ចំណុចដៅ WASH MIS: ៣០០) |

**<u>ចតុកោណទី ២</u> : <u>ការធ្វើពិពិធកម្មសេដ្ឋកិច្ច</u>** - ការធ្វើពិពិធកម្មសេដ្ឋកិច្ចជាដំណើរការចាំបាច់ នៃការបង្កើតចន្លោះឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រីកការនាំចេញ ឬបង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ក្នុងរយៈពេលមធ្យម និងវែងខាងមុខ តាមរយៈការផ្តោតលើអាទិភាពចំនួន ៤ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក គឺ ១) ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន, ថាមពល និងឌីជីថល; ២) ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ; ៣) ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ និង៤) ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ (ទំ. ៥៥) ។

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ និង សមាហរណកម្មតំបន់**<br>ការកែលម្អប្រព័ន្ធឡូជីស្ទីក និងការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន, ថាមពល និងឌីជីថល | ១. ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដោយធ្វើការលើកកម្រិតផ្លូវ និងពង្រីកទទឹងផ្លូវ ប្រកបដោយគុណភាព, កែលម្អប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែក និងពង្រីកកំពង់ផែ | ១.១. បញ្ចូលផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូន ជាមួយនឹងផែនការមេភស្តុភារកម្ម ក៏ដូចជាការផ្តួចផ្តើមធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលភស្តុភារកម្មរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលភស្តុភារកម្មខេត្តព្រះសីហនុ ក្រោមគម្រោងអភិវឌ្ឍន៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)។ ចំណុចដៅ២០១៩-២០២០:<br>- ឆ្នាំ២០២០ បញ្ចប់ការរៀបចំផែនការមេថ្នាក់ជាតិ ស្តីពីការដឹកជញ្ជូន និងភស្តុភារកម្ម<br>- ឆ្នាំ២០២០ បញ្ចប់ការផ្តួចផ្តើមគម្រោងធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលភស្តុភារកម្មរាជធានីភ្នំពេញ (PP-LC) និងមជ្ឈមណ្ឌលភស្តុភារកម្មខេត្តព្រះសីហនុ (SHV-LC) ក្រោមគម្រោងអភិវឌ្ឍន៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)<br>១.២. ការស្តារ និងសាងសង់ផ្លូវជាតិ (ចំណុចដៅ២០១៩-២០២០: ចាប់ផ្តើមស្តារ និងសាងសង់ផ្លូវជាតិលេខ៥; លេខ៧1C; លេខ១០; លេខ៤៨ និងលេខ៤ នៅក្នុងឆ្នាំ២០២០)<br>១.៣. អភិវឌ្ឍចំណតកំពង់ផែកុងតឺន័រថ្មី និងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ (Port EDI)។ ចំណុចដៅ២០១៩-២០២០:<br>- ចាប់ផ្តើមសាងសង់ចំណតកំពង់ផែកុងតឺន័រថ្មីខេត្តព្រះសីហនុ (ប្រវែង៣៥០ម៉ែត្រ និងជម្រៅទឹក ១៤,៥៥ម៉ែត្រ) ឆ្នាំ២០២០<br>- ធ្វើទំនើបកម្មបន្ទប់បញ្ជូនផលីយកំណ្ឌផែ និងសេវាកម្ម (ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ Port EDI) ឆ្នាំ២០២០<br>១.៤. ស្វែងរកដំណោះស្រាយកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ (ចំណុចដៅ២០១៩-២០២០: បញ្ចប់ការសិក្សាប្រព័ន្ធរថភ្លើងដឹកជញ្ជូនស្វ័យប្រវត្តិ (AGT); រថភ្លើងធុនស្រាល (Tramway) និងរថភ្លើងលើអាកាស (Monorail) ឆ្នាំ២០២០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ២. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ | ២.១. ផ្លូវជនបទប្រវែង ៥២៦៨ គ.ម ត្រូវបានស្ដាបនា និងតភ្ជាប់ជាបណ្ដាញ សំដៅលើកកម្ពស់វិស័យហេដ្ឋារចនាសម្ព័ន្ធ (បន្ទាត់មូលដ្ឋានៈ ១.៥៦៨ គ.ម; ចំណុចដៅ: ៥.២៦៨ គ.ម [ឆ្នាំ២០១៩: ២.១៩៥ គ.ម, ឆ្នាំ២០២០: ៣.០៧៣ គ.ម]) ទិន្នន័យផ្ទៀងផ្ទាត់ៈ ផែនការប្រចាំឆ្នាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ<br>២.២. ផ្លូវជនបទប្រវែង ៧៣៣ គ.ម ត្រូវបានកែលម្អទៅជាផ្លូវកៅស៊ូពីរជាន់ ឬបេតុង ដើម្បីឱ្យមានភាពធន់នឹងបញ្ហាបម្រែបម្រួលអាកាសធាតុ (បន្ទាត់មូលដ្ឋានៈ ៣៣០ គ.ម; ចំណុចដៅ: ៧៣៣ គ.ម [ឆ្នាំ២០១៩: ៣៥១គ.ម ឆ្នាំ២០២០: ៣៨២គ.ម]) ទិន្នន័យផ្ទៀងផ្ទាត់ៈ ផែនការប្រចាំឆ្នាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ៣. ពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍, បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថលឱ្យដល់ទីជនបទដាច់ស្រយាល និងតំបន់មានសក្ដានុពលខាងសេដ្ឋកិច្ច និងទេសចរណ៍ | ៣.១. ការពង្រីកវិសាលភាពគ្របដណ្ដប់អ៊ីនធឺណេតល្បឿនលឿន ឱ្យដល់ទីប្រជុំជន (ចំណុចដៅ២០២០: ១០០%)<br>៣.២. ការពង្រីកវិសាលភាពគ្របដណ្ដប់អ៊ីនធឺណេតល្បឿនលឿន ឱ្យដល់ទីជនបទ (ចំណុចដៅ២០២០: ៧០%) |

**ចតុកោណទី ៣ : ការអភិវឌ្ឍវិស័យឯកជន** - ការអភិវឌ្ឍវិស័យឯកជននៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារ និងមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការអភិវឌ្ឍវិស័យឯកជននឹងត្រូវបានអនុវត្តតាមរយៈវិធានការជាកញ្ចប់ និងគ្រប់ជ្រុងជ្រោយដោយគ្របដណ្ដប់មុំ ៤ គឺ ១) ការអភិវឌ្ឍទីផ្សារការងារ; ២) ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព; ៣) ការរៀបចំ និងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និង ៤) ការពង្រឹងការប្រកួតប្រជែង (ទំ. ៦៥) ។

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ការអភិវឌ្ឍវិស័យឯកជន*** <br> កិច្ចសម្រួលពាណិជ្ជកម្ម ត្រូវបន្តពង្រឹងតាមរយៈការបញ្ចប់នូវការរៀបចំប្រព័ន្ធបញ្ជរជាតិតែមួយ, ការកែលម្អយន្តការត្រួតពិនិត្យនៅតាមព្រំដែនឱ្យស្ថិតក្នុងកម្រិតអប្បបរមា និងការបន្តកាត់បន្ថយនីតិវិធីទាក់ទង និងពាណិជ្ជកម្ម | ១. ស្វ័យប្រវត្តិកម្មនៃបែបបទនីតិវិធីរបស់ទីភ្នាក់ងារតាមព្រំដែនសំខាន់ៗ នឹងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងពេលវេលា/ការចំណាយ <br> ២. ប្រព័ន្ធបញ្ជរជាតិតែមួយ ត្រូវបានរៀបចំបញ្ចប់ | ១. ពង្រឹង និងពង្រីកបន្ថែមការវិនិយោគលើការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម <br> ២. បញ្ចប់ការធ្វើឱ្យប្រសើរឡើង និងសមាហរណកម្មនូវប្រព័ន្ធ÷ <br> - អនាម័យ និងភូតគាមអនាម័យ (SPS) <br> - និហិតដ្ឋានព័ត៌មានពាណិជ្ជកម្មកម្ពុជា <br> - សមាសភាគនៃប្រព័ន្ធបញ្ជរជាតិតែមួយ ត្រូវបានរៀបចំ |
| បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ ដែលកើតចេញពីកំណែទម្រង់ច្បាប់, ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌការលើកទឹកចិត្តវិនិយោគ និងភាពប្រសើរឡើងនៃភាពប្រកួតប្រជែង | ១. ចំនួនអ្នកវិនិយោគមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង | ១.១. ចំនួនអ្នកវិនិយោគមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១០% |
| | ២. ចំនួនទុនវិនិយោគ និងគម្រោងដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង | ២.១. ចំនួនទុនវិនិយោគដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ២០% <br> ២.២. ចំនួនគម្រោងដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១០% |
| | ៣. ចំនួនការងារកើនឡើងបន្ថែម | ៣.១. ចំនួនការងារកើនឡើងបន្ថែម ៥% |

__ចតុកោណទី ៤ : ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន__-រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹង **"គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា"** ដែលតម្រូវឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ ១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ; ២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយចីរភាព; ៣) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង ៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ទំ. ៧៥)។

* សូចនាករតាមដានត្រូវបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **វិស័យកសិកម្ម និងទឹក**<br><br>ជំរុញកំណើនកសិកម្ម តាមរយៈការលើកកម្ពស់ភាពប្រកួតប្រជែង, គុណភាពផលិតផល, សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព និងធានាបានធនធានទឹក ដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព, សមធម៌, ចីរភាព និងជួយដល់ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងកាត់បន្ថយបាននូវគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ និងទ្រព្យសម្បត្តិសាធារណៈ | ១. ធ្វើឱ្យប្រសើរឡើងផលិតភាពកសិកម្ម និងពិពិធកម្មផលិតផលនាំចេញ | ១.១. ផលិតភាពដីកសិកម្ម (បន្ទាត់មូលដ្ឋាន២០១៨: ១.៦៧១ ដុល្លារ/ ហ.ត; ចំណុចដៅ២០២០: ១.៨០៤ ដុល្លារ/ ហ.ត)<br>១.២. ផលិតភាពពលកម្មកសិកម្ម (បន្ទាត់មូលដ្ឋាន២០១៨: ១.៧៦៤ ដុល្លារ/ក្នុងមួយកសិករ; ចំណុចដៅ២០២០: ២.០០០ ដុល្លារ/ក្នុងមួយកសិករ)<br>១.៣. ការបង្កើនសមាមាត្រនៃពិពិធកម្មដំណាំ (គិតជាភាគរយ) (បន្ទាត់មូលដ្ឋាន២០១៨: ៦២,៣២; ចំណុចដៅ២០២០:៦៤,៥៥)<br>១.៤. ការបង្កើនសមាមាត្រនៃពិពិធកម្មដំណាំ (បន្ទាត់មូលដ្ឋាន២០១៨: ៥,៤៩ លានតោន; ចំណុចដៅ២០២០: ៦,២៩ លានតោន) |
| | ២. លើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | ២.១. ការបង្កើនផលិតកម្មសាច់សរុប (បន្ទាត់មូលដ្ឋាន២០១៨: ២៣១ ពាន់តោន; ចំណុចដៅ២០២០: ២៧០ ពាន់តោន) |
| | ៣. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានទឹក (កិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ [ក.ដ.ថ] និងការអភិវឌ្ឍសហគមន៍កសិករប្រើប្រាស់ទឹក [ស.ក.ប.ទ]) ព្រមទាំងអភិវឌ្ឍ និងធ្វើអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ | ៣.១. ពង្រីកលទ្ធភាពស្រោចស្រពបំពេញបន្ថែម (IS) ចំនួន ៣០.០០០ ហ.ត/ឆ្នាំ (បន្ទាត់មូលដ្ឋាន២០១៨: ១.៨០២.៣៥៩ ហ.ត; ចំណុចដៅ២០២០: ១.៨៦២.៣៥៩ ហ.ត)<br>៣.២. ពង្រីកលទ្ធភាពស្រោចស្រពបំពេញបន្ថែម (IS) សម្រាប់ដំណាំរួមផ្សំចំនួន ៥០០ ហ.ត/ឆ្នាំ (បន្ទាត់មូលដ្ឋាន២០១៨: ៤.៤១៣ ហ.ត; ចំណុចដៅ២០២០: ៥.៤១៣ ហ.ត)<br>៣.៣. ពង្រីកលទ្ធភាពបង្កើត ស.ក.ប.ទ ចំនួន០៧/ឆ្នាំ (បន្ទាត់មូលដ្ឋានៈ ៥៤៤ ស.ក.ប.ទ; ចំណុចដៅ២០២០: ៥៥៨ ស.ក.ប.ទ)<br>៣.៤. ពង្រីកលទ្ធភាពកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រចំនួន ៤១ ប្រព័ន្ធ/ឆ្នាំ (បន្ទាត់មូលដ្ឋានៈ ២០៧ ប្រព័ន្ធ; ចំណុចដៅ២០២០: ២៩០ ប្រព័ន្ធ)<br>៣.៥. ពង្រីកលទ្ធភាព និងពង្រឹងសមត្ថភាព ស.ក.ប.ទ បន្ថែមចំនួន ១៥/ឆ្នាំ (បន្ទាត់មូលដ្ឋាន២០១៨: ១០៣ ស.ក.ប.ទ; ចំណុចដៅ២០២០: ១៣៣ ស.ក.ប.ទ) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ការកែទម្រង់ព្រៃឈើ**<br><br>ត្រូវបានបង្កើន និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រកបដោយនិរន្តរភាព រួមមាន ធនធានព្រៃផ្តល់ផលសហគមន៍ព្រៃឈើ និងសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់, ការដាំព្រៃឈើឡើងវិញ, ការស្តារតំបន់ទេសភាពព្រៃឈើ, ការស្រាវជ្រាវ និងការអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ និងការបង្កើនជីវភាពសហគមន៍ព្រៃឈើ | ១. ការគ្រប់គ្រងព្រៃផ្តល់ផល និងសហគមន៍ព្រៃឈើបានប្រសើរឡើង | ១.១. ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន ៤០ (២០សហគមន៍ព្រៃឈើ / ឆ្នាំ) ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន២០១៨: ៨៥ សហគមន៍ព្រៃឈើ)<br>១.២. សហគមន៍ព្រៃឈើចំនួន ៤១ ទទួលបានហិរញ្ញប្បទានសម្រាប់គម្រោងបង្កើនជីវភាព (បន្ទាត់មូលដ្ឋាន២០១៨: ២១ សហគមន៍ព្រៃឈើ ទិន្នន័យពី RECOFTC)<br>១.៣. ផ្ទៃដីព្រៃឈើរេចរឹលទំហំ ៥០០ ហ.ត ត្រូវដាំដើមឈើឡើងវិញ (បន្ទាត់មូលដ្ឋាន២០១៨: ២២០ ហ.ត)<br>១.៤. កូនឈើចំនួន ១០លានដើម ត្រូវបានចែកជូនសាធារណជន និងសហគមន៍មូលដ្ឋាន (បន្ទាត់មូលដ្ឋាន២០១៨: ១,២លានដើម) |
| | ២. ធនធានជីវចម្រុះត្រូវបានការពារ និងគុណភាពកើនឡើង | ២.១. សត្វព្រៃចំនួន ១.៦០០ (៨០០សត្វ/ឆ្នាំ) ត្រូវបានសង្គ្រោះ និងដោះលែង (បន្ទាត់មូលដ្ឋាន២០១៨: ១.៤៨៤សត្វ)<br>២.២. ឡូត៍ពិសោធន៍ដាំពូជឈើទំហំ ៥០ ហ.ត ត្រូវបានបង្កើត (បន្ទាត់មូលដ្ឋាន២០១៨: ២០ហ.ត) |
| | ៣. ការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាព | ៣.១. តំណាងសហគមន៍ព្រៃឈើចំនួន ២០០នាក់ ក្នុង ១ឆ្នាំ ទទួលបានការបណ្តុះបណ្តាល និងចូលរួមកិច្ចប្រជុំពិគ្រោះយោបល់<br>៣.២. ផែនទីចង្អុលផ្លូវសម្រាប់ពង្រឹងការអនុវត្តច្បាប់ព្រៃឈើ, អភិបាលកិច្ច និងពាណិជ្ជកម្ម (FLEGT roadmap) ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន: 0) |
| | ៤. ផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងព្រៃផ្តល់ផល និងសហគមន៍ព្រៃឈើត្រូវបានរៀបចំ | ៤.១. ក្របខណ្ឌសម្រាប់ការតាមដានសូចនាករតាមដានរួមគ្នា (JMI) ត្រូវបានពិនិត្យឡើងវិញ (បន្ទាត់មូលដ្ឋាន: 0) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| **ការកែទម្រង់ជលផល**<br><br>ពង្រឹងការអភិវឌ្ឍ និងគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | ១. ផលត្រីចាប់ពីធម្មជាតិរក្សាបានក្នុងកម្រិតថេរ | ១.១. ផលត្រីចាប់ពីធម្មជាតិពីគ្រប់ប្រភព រក្សាបានក្នុងបរិមាណ ៦០០.០០០ តោន ក្នុងមួយឆ្នាំ រួមទាំងផលនេសាទសមុទ្រប្រមាណ ១០០.០០០តោន [ចំណុចដៅក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល] (បន្ទាត់មូលដ្ឋាន២០១៨: ៦៥៦.១០៥ តោន រួមបញ្ចូល ១២១.១០០តោន ពីផលនេសាទសមុទ្រ; ចំណុចដៅ២០២០: ៦០០.០០០ តោន)<br>១.២. តំបន់អភិរក្សជលផលរបស់រដ្ឋ ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈវិធីសាស្ត្រវាយតម្លៃប្រសិទ្ធភាពតំបន់អភិរក្សជលផល ដោយរដ្ឋបាលជលផល (បន្ទាត់មូលដ្ឋាន២០១៨: ៦៦.១២០ ហ.ត នៃតំបន់អភិរក្សជលផលទឹកសាប ត្រូវបានវាយតម្លៃថាបានការពារប្រកបដោយប្រសិទ្ធភាព (មិនមានបន្ទាត់មូលដ្ឋានសម្រាប់តំបន់អភិរក្សសមុទ្រ); ចំណុចដៅ២០២០: ១៤២.១៣៥ ហ.ត [SPF])<br>១.៣. ចំនួនសហគមន៍នេសាទ ដែលត្រូវបានផ្តល់ចំណាត់ថ្នាក់ជាសហគមន៍ល្អ តាមរយៈការវាយតម្លៃអំពីប្រសិទ្ធភាពសហគមន៍ ដោយរដ្ឋបាលជលផល និងផ្ទៃដីសរុបនៃកន្លែងអភិរក្សសហគមន៍នេសាទត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព (បន្ទាត់មូលដ្ឋាន២០១៨: ៣៣សហគមន៍; ចំណុចដៅ២០២០: ១៥០សហគមន៍ [ASDP])<br>១.៤. ចំនួនសហគមន៍ស្រះជម្រកត្រី ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព (បន្ទាត់មូលដ្ឋាន២០១៨: នឹងកំណត់; ចំណុចដៅ២០២០: ១៧៥សហគមន៍ [ក្នុងចំណោមសហគមន៍សរុបចំនួន ៨៧០]) |
| | ២. ផលិតផលវារីវប្បកម្មកើនឡើង ២០%ក្នុងមួយឆ្នាំ | ២.១. ចំនួនកូនត្រីពូជ ផលិតបានពីកន្លែងបង្កាត់ភ្ញាស់ក្នុងស្រុក (បន្ទាត់មូលដ្ឋាន២០១៨: ២១០.០០០.០០០ក្បាល; ចំណុចដៅ២០២០: ៣០០.០០០.០០០ក្បាល [ASDP]) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|
| | ៣. លើកកម្ពស់គុណភាព និងសុវត្ថិភាព នៃផលិតផលដែលបានពីវារីវប្បកម្ម និងធម្មជាតិ | ៣.១. ចំនួនទីតាំងចិញ្ចឹម និងកែច្នៃ ទទួលនិមិត្តសញ្ញាគុណភាព និង/ឬ វិញ្ញាបនបត្របញ្ជាក់ស្តង់ដារ HACCP [ASDP] (បន្ទាត់មូលដ្ឋាន២០១៧: ២; ចំណុចដៅ២០២០: ១០) |
| **វិស័យមីន**<br><br>កម្មវិធីសកម្មភាពមីនជាតិ ឆ្លើយតបនឹងបញ្ហាសន្តិសុខមនុស្សជាតិ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១. ដីដែលដឹងថាមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) បានបោសសម្អាតរួច ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១.១. រំដោះផ្ទៃដីសង្ស័យមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឱ្យបាន ២១.៤០០ ហ.ត/១ឆ្នាំ<br>១.២. ផ្ទៃដីដែលបានសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមរួចទាំងអស់ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម |
| | ២. កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីន/ស.ផ.ស. | ២.១. ចំនួនជនរងគ្រោះដោយសារមីន/ស.ផ.ស. ត្រូវបានថយចុះ ១០% ក្នុងមួយឆ្នាំ |
| | ៣. ជនរងគ្រោះដោយសារមីន/ស.ផ.ស បានយល់ដឹងពីសិទ្ធិ និងទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាស្តារលទ្ធភាពពលកម្ម, កាយសម្បទា ព្រមទាំងលើកកម្ពស់ការស្វែងរកការគាំទ្រមតិសម្រាប់ជនពិការនៅក្នុងវេទិកាជាតិនិងអន្តរជាតិ | ៣.១. ជនរងគ្រោះដោយសារមីន/ស.ផ.ស.ចំនួន ១.០០០នាក់ បានយល់ដឹងពីសិទ្ធិរបស់ពួកគេ និងការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាស្តារលទ្ធភាពពលកម្ម និងកាយសម្បទា<br>៣.២. ជនរងគ្រោះដោយសារមីន/ស.ផ.ស. ចំនួន ៣.០០០នាក់ បានទទួលការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាស្តារលទ្ធភាពពលកម្ម និងកាយសម្បទា<br>៣.៣. ការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរមីនក្នុងវេទិកាកិច្ចប្រជុំជាតិ និងអន្តរជាតិ ដើម្បីគាំទ្រ និងលើកស្ទួយជនរងគ្រោះដោយសារមីន/ស.ផ.ស. |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) | | សូចនាករលទ្ធផលក្នុងឆ្នាំ (២០១៩-២០២០) |
|---|---|---|---|
| **ការប្រែប្រួលអាកាសធាតុ*** <br><br> កម្រិតត្រៀមរបស់ស្ថាប័ន ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (CSDG គោលដៅ ១៣ និង NSDP) - ផ្នែកព័តិមាន | ១. បច្ចុប្បន្នកម្មឯកសារការចូលរួមចំណែករបស់កម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Cambodia NDC) ត្រូវបានស្នើជាផ្លូវការទៅលេខាធិការដ្ឋាន UNFCCC អនុលោមតាមលក្ខខណ្ឌ UNFCCC | ១.១. | ស្ថានភាពនៃបច្ចុប្បន្នកម្មឯកសារ NDC ស្នើជូនទៅ UNFCCC (បន្ទាត់មូលដ្ឋាន២០១៨: មិនទាន់បានដាក់ឯកសារជូនទៅ UNFCCC; ចំណុចដៅ ២០២០: បានដាក់ជូនឯកសារទៅ UNFCCC) |
| | ២. ប្រព័ន្ធតាមដាន, រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) សម្រាប់ការប្តេជ្ញារបស់កម្ពុជា ស្របតាម NDC ត្រូវបានដាក់ឱ្យដំណើរការ | ២.១. | ស្ថានភាពនៃប្រព័ន្ធ MRV សម្រាប់ Cambodia NDC (បន្ទាត់មូលដ្ឋាន២០១៨: មិនទាន់ដំណើរការ; ចំណុចដៅ២០២០: បានដំណើរការ) |

* សូចនាករតាមដានត្រូវបានកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន សម្រាប់ការអនុវត្ត និងតាមដានវឌ្ឍនភាព